ក

មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៣-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៩៤ ស្ដីពីការតែងតាំង ឯកឧត្ដម **សោម សត្ថា** ជាទីប្រឹក្សា ឯកឧត្ដម **តែង ពុន្ធរស្មី** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការ សាសនា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយមិនទទួលប្រាក់បៀវត្ស ២៤៤៥

២៣-០២-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៩៥ ស្ដីពីការតែងតាំង ឯកឧត្ដម **ហួយ គឹមអាន** ជាទីប្រឹក្សាបច្ចេកទេស អមវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិ នៃរាជបណ្ឌិតសភាកម្ពុជា មានឋានៈស្មើ អគ្គនាយក ២៤៤៦

០២-៣-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៩៧ ស្ដីពីការកែសម្រួលថ្នាក់ ក្នុងឋានន្តរស័ក្តិ ឧត្ដមមន្ត្រី ជូនមន្ត្រីរាជការ ២៤៤៧

០២-៣-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៩៨ ស្ដីពីការតែងតាំង ឯកឧត្ដម **ញឹម ម៉ូចាន** ជាអគ្គលេខាធិការរង នៃក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានឋានៈស្មើ អគ្គនាយក ២៤៥០

០២-៣-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/០៩៩ ស្ដីពីការតែងតាំងមន្ត្រីរាជការ ២៤៥១

០២-៣-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០២០៧/១០០ ស្ដីពីការផ្ទេរក្របខ័ណ្ឌ លោក **អ៊ុំ សារឿន** ពីអនុមន្ត្រីថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅក្រសួងពាណិជ្ជកម្ម មកជាអនុមន្ត្រី ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ២៤៥២

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

០៥-៣-២០០៧ -អនុក្រឹត្យលេខ ១៧ អនក្រ.បក ស្ដីពីការកំណត់ប្រាក់ឧបត្ថម្ភ ចំពោះប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ២៤៥៣

០៥-៣-២០០៧ -អនុក្រឹត្យលេខ ១៨ អនក្រ.បក ស្ដីពីការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ ២៤៥៥

០៥-៣-២០០៧ -អនុក្រឹត្យលេខ ១៩ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ២៤៦០

០៧-៣-២០០៧ -អនុក្រឹត្យលេខ ២០ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួង សម្រាប់អនុវត្តកាតព្វកិច្ច និងការសន្យារបស់កម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក ២៤៦២

០៥-៣-២០០៧ -អនុក្រឹត្យលេខ ១៨៧ អនក្រ.តត ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តភ្នំពេញ " ក.ស.ភ" ២៤៧២

០៥-៣-២០០៧ -អនុក្រឹត្យលេខ ១៨៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៤៧៤

២-សេចក្តីសំរេច

០៧-៣-២០០៧ -សេចក្តីសំរេចលេខ ១២ សសរ ស្តីពី ការកែសម្រួលសេចក្តីសម្រេចស្តីពីការកែសម្រួលសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារតាមវិស័យសម្រាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន ២៤៨២

III-ការងារបណ្តាក្រសួង

ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៨-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣១១៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(ខេមបូឌា) គ្លូប៊ល អ៊ិនស្ទូរេន ខូអបពើរេសិន** ២៤៨៦

០៨-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣១១៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គិច គីម ម៉ាញ ឌីវេឡុបមេន** ២៤៨៨

០៨-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣១១៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជីធី (ខេមបូឌា) អ៊ិនវេសមេន ខមភេនី** ២៤៩០

០៨-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣១១៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទេសធើន អេឃ្វីបមេន** ២៤៩២

០៨-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣១១៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជុំខ ណាយ គ្រូចេះ អេតិចឡង់ កៅស៊ូ** ២៤៩៤

១៣-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣១២២ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(ខេមបូឌា) ឌីវេឡុបមេន ហ្គោល គ្រុប អិលធីឌី** ២៤៩៦

១៣-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣១២៧ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម.អេស.អិម. ស៊ុយអ៊្វីធី (ខេមបូឌា) ខូ អិលធីឌី** ២៤៩៨

១៣-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣១២៩ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាម៉ៅ ចាឌី** ២៥០០

១៣-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣១៣០ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទីទ្វ (ខេមបូឌា)** ២៥០២

១៥-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣១៣៤ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យូនីធី អិម ធី ធី អេស (ខេមបូឌា)** ២៥០៤

១៥-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣១៣៧ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខ្មែរ មីនើរ៉ល ឌីវេឡុបមេន (ខេ.អិម.ឌី)** ២៥០៦

១៥-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣១៣៩ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស ធី អេច ខូ អិលធីឌី** ២៥០៨

១៥-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣១៤០ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី.ខេ.ឡាពីដារី** ២៥១០

១៥-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣១៤១ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មី នាង (ខេមបូឌា)** ២៥១២

១៨-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣១៥៥ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីកម៉ាអស៊ី (ខេមបូឌា)** ២៥១៤

១៨-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣១៥៧ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **បេស អុកស៊ីរ៉ាស ទ័រើរ (ខេមបូឌា)** ២៥១៦

១៨-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣១៥៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ ស៊ី អាយ គ្រុប** ២៥១៨

១៨-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣១៥៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មៀង សុក ខូ អិលធីឌី** ២៥២០

១៨-១២-២០០៦ -លិខិតបញ្ជាក់លេខ ៣១៦០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចិញ ឡុង ក្រចេះ អភិវឌ្ឍន៍ កៅស៊ូ** ២៥២២

ព្រះរាជក្រឹត្យ

នស/រកត/០២០៧/០៩៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំង ឯកឧត្តម សោម សត្ថា ជាទីប្រឹក្សា ឯកឧត្តម កែប ពុទ្ធរស្មី ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការ សាសនា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយមិនទទួលប្រាក់បៀវត្ស ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧ល.០៧០២.១០៤

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ២០០៧

លេខ: ១១៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ០៣ ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ឌិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០២០៧/០៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំងឯកឧត្តម ហួយ គឹមអាន ជាទីប្រឹក្សាបច្ចេកទេសអមវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិ នៃរាជបណ្ឌិតសភាកម្ពុជា មានឋានៈស្មើ អគ្គនាយក ។

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៣ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រា.០៧០២.១០៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៧

លេខ:១២០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ៣ ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

យុន ជីនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៣០៧/០៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សាខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរារាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៩ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានកែសម្រួលថ្នាក់ ក្នុងឋានន្តរសក្តិឧត្តមមន្ត្រី ជូនមន្ត្រីរាជការដូចខាងក្រោម :

១	ឯកឧត្តម ពេជ សោភ័ន	ពីឧត្តមមន្ត្រីថ្នាក់លេខ ៣	ទៅឧត្តមមន្ត្រីថ្នាក់លេខ ១
២	ឯកឧត្តម អ៊ុច បូរិទ្ធ	ពីឧត្តមមន្ត្រីថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រីថ្នាក់លេខ ២

មាត្រា ២ : ត្រូវបានតម្លើងឋានន្តរសក្តិពីវរមន្ត្រីទៅ ឋានន្តរសក្តិឧត្តមមន្ត្រីដូចខាងក្រោម :

១-ក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ :

៣	ឯកឧត្តម លន់ គីមឃួន	ពីវរមន្ត្រីថ្នាក់លេខ ៥	ទៅឧត្តមមន្ត្រីថ្នាក់លេខ ៦
៤	ឯកឧត្តម ថៃ ចណ្ណា	ពីវរមន្ត្រីថ្នាក់លេខ ៥	ទៅឧត្តមមន្ត្រីថ្នាក់លេខ ៦

២- ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល :

៥	លោក ធី សារ៉ាន	ពីវរមន្ត្រីថ្នាក់លេខ ២	ទៅឧត្តមមន្ត្រីថ្នាក់លេខ ៣
៦	លោក ជឹម ខួន	ពីវរមន្ត្រីថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រីថ្នាក់លេខ ៣
៧	ឯកឧត្តម ឈៅ ឆូត	ពីវរមន្ត្រីថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រីថ្នាក់លេខ ៣
៨	លោក ប៊ុត បូទុត	ពីវរមន្ត្រីថ្នាក់លេខ ៣	ទៅឧត្តមមន្ត្រីថ្នាក់លេខ ៤
៩	ឯកឧត្តម ធី សុគន្ធ	ពីវរមន្ត្រីថ្នាក់លេខ ៨	ទៅឧត្តមមន្ត្រីថ្នាក់លេខ ៥
១០	ឯកឧត្តម ឈាត ប៊ុនរឿន	ពីវរមន្ត្រីថ្នាក់លេខ ៤	ទៅឧត្តមន្ត្រីថ្នាក់លេខ ៥

មាត្រា ៣ : ត្រូវបានកែសម្រួលក្របខ័ណ្ឌមន្ត្រីរាជការដូចខាងក្រោម :

១១	ឯកឧត្តម ចាន់ គីស៊ីម	កែសម្រួលពី ឋានន្តរសក្តិឧត្តមមន្ត្រីថ្នាក់លេខ ៦ នៃ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល	ទៅឋានន្តរសក្តិឧត្តមមន្ត្រីថ្នាក់លេខ ៦ នៃ ក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
១២	ឯកឧត្តម ជុំ សុន្ទរី	កែសម្រួលពី ឋានន្តរសក្តិឧត្តមមន្ត្រីថ្នាក់លេខ ៦ នៃ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល	ទៅឋានន្តរសក្តិឧត្តមមន្ត្រីថ្នាក់លេខ ៦ នៃ ក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
១៣	ឯកឧត្តម ជីង ប៊ុនថេង	កែសម្រួលពី ឋានន្តរសក្តិឧត្តមមន្ត្រីថ្នាក់លេខ ៦ នៃ ក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល	ទៅឋានន្តរសក្តិឧត្តមមន្ត្រីថ្នាក់លេខ ៦ នៃ ក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

ROYAUME DU CAMBODGE • MINISTÈRE DU PALAIS ROYAL

មាត្រា ៦ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣/ល.០៧០៣.១០៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០០៧

លេខ: ១២១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៣០៧/០៩៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគុមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/១៧២ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសមាសភាព នៃក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម **ញឹម មូខាន** ជាអគ្គលេខាធិការរង នៃក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានឋានៈស្មើ **អគ្គនាយក** ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧.០៧០៣.១០៩

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០០៧

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៧

ព្រះរាជក្រឹត្យ

នស/រកត/០៣០៧/០៩៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគុមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានតែងតាំង :

១- ឯកឧត្តម ជា សុផាត ជាទីប្រឹក្សា ឯកឧត្តម កែវ ពុទ្ធរស្មី ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

២- ឯកឧត្តម ខឹម ជា ជាទីប្រឹក្សា ឯកឧត្តម លី ឡាយស្រេង ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

៣-ឯកឧត្តម ជ៉ាង ខួនតា ជាទីប្រឹក្សា ឯកឧត្តម ញ៉ឹក ប៊ុនឆៃ ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣/ល.០៧០៣-១០៩

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ.ថ្ងៃទី ៤ ខែ មីនា ឆ្នាំ២០០៧

លេខ: ១២៣៦.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៣ ឆ្នាំ២០០៧
រដ្ឋលេខាធិការអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

ឃុន ឌីនភេន

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៣០៧/១០០

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤/ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានផ្ទេរក្របខ័ណ្ឌ លោក អ៊ុំ សារឿន ពីអនុមន្ត្រីថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅក្រសួងពាណិជ្ជកម្ម មកជាអនុមន្ត្រី ថ្នាក់លេខ ៦ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ៗ.ល. ០៧០៣.១១០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០០៧

លេខ ១២៥ ច.ល
ថ្ងៃទី ខែ ០២ ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភ
ចំពោះប្រធានភូមិ អនុប្រធានភូមិ និងសមាជិកភូមិ

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៤ ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែ ធ្នូ ឆ្នាំ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០២ និងត្រូវបានកែប្រែដោយច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦
- បានឃើញព្រះរាជក្រមលេខនស/រកម/០៣០១/០៥ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៥៥ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦ ដែលបង្កើតគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីមូលនិធិឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០០៥ ស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់
- បានឃើញសេចក្តីណែនាំលេខ ០០៤ ស.ណ.ន ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០០៦ ស្តីពីបែបបទនីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ របស់ក្រសួងមហាផ្ទៃ

- យោងស្មារតីអង្គប្រជុំរបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនាថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៧
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

មាត្រា ១ : ត្រូវបានកំណត់ប្រាក់ឧបត្ថម្ភប្រចាំខែចំពោះមន្ត្រី ភូមិដូចខាងក្រោម:
១-ប្រធានភូមិ ៤០.០០០ រៀលក្នុងមួយខែ " បួនម៉ឺនរៀល "
២-អនុប្រធានភូមិ ៣០.០០០ រៀលក្នុងមួយខែ " បីម៉ឺនរៀល "
៣-សមាជិកភូមិ ២០.០០០ រៀលក្នុងមួយខែ " ពីរម៉ឺនរៀល " ។

មាត្រា ២ : ប្រាក់ឧបត្ថម្ភចំពោះមន្ត្រី ភូមិដែលបានកំណត់ក្នុងមាត្រា១ខាងលើ ត្រូវផ្តល់ជូនតែក្នុងរយៈពេលនៃមុខតំណែង និងមានសេចក្តីសំរេចតែងតាំងជាផ្លូវការរបស់មេឃុំ ឬចៅសង្កាត់ ។ ប្រាក់ឧបត្ថម្ភនេះត្រូវគ្រោង និងបើកផ្តល់នៅក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ដោយគិតចាប់តាំងពីខែមករា ឆ្នាំ ២០០៧ ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី.....១៥.....ខែ.....មីនា.....ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ស.ខ ១៣២

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចចែងក្នុងមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ១៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

មាត្រា ១.-

បង្កើតគណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ.ភ.ខ) ទទួលបន្ទុកកំណត់ឯកភាពនៃការប្រើប្រាស់ភាសាខ្មែរ ដែលមានសមាសភាពដូចតទៅ ÷

១-ឯកឧត្តមបណ្ឌិត **សុខ អាន**	ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី	**ប្រធាន**
២-ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ឡុង សៀម**	អនុប្រធានរាជបណ្ឌិតសភាកម្ពុជា	**អនុប្រធានអចិន្ត្រៃយ៍**
៣-ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ញ៉ី ម៉ល់**	ទីប្រឹក្សាអមទីស្ដីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកផ្នែកភាសាវិទ្យា	**អនុប្រធាន**
៤-ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ស៊ុំ ឈុំប៊ុន**	អគ្គលេខាធិការនៃរាជបណ្ឌិតសភាកម្ពុជា	**អគ្គលេខាធិការ**
៥-លោកសាស្ត្រាចារ្យបណ្ឌិត **អ៊ឹម ច័ន**	អនុប្រធានវិទ្យាស្ថានភាសាជាតិ	**អគ្គលេខាធិការរង**
៦-លោកអគ្គបណ្ឌិត **ប៊ុត សាខឿ**		**ទីប្រឹក្សា**
៧-ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ស៊ន សំណាង**	ប្រធានរាជបណ្ឌិតសភាកម្ពុជា	**ទីប្រឹក្សា**
៨-ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ឆយ យីហ៊ាង**	អនុប្រធានរាជបណ្ឌិតសភាកម្ពុជា	**ទីប្រឹក្សា**
៩-ព្រះតេជគុណ **យស ហ៊ុត**	ប្រធានស្ដីទីសមាគមធម្មទូត និងជាប្រធានមូលនិធិពុទ្ធសាសនាខ្មែរ-វត្តធម្មរង្សី	**សមាជិក**
១០-លោកជំទាវសាស្ត្រាចារ្យបណ្ឌិត **ខួត ធីតា**	អនុប្រធានរាជបណ្ឌិតសភាកម្ពុជា	**សមាជិក**
១១-ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **រស់ ចន្ទ្រាបុត្រ**	អនុប្រធានរាជបណ្ឌិតសភាកម្ពុជា	**សមាជិក**
១២-ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ជា ណេង**	អនុប្រធានរាជបណ្ឌិតសភាកម្ពុជា	**សមាជិក**
១៣-ឯកឧត្តមសាស្ត្រាចារ្យវេជ្ជបណ្ឌិត **សំ សោភាន់**	ប្រធានវិទ្យាស្ថាន ជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម	**សមាជិក**
១៤-ឯកឧត្តមបណ្ឌិតរដ្ឋ **តិច សំណាង**	អគ្គលេខាធិការគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា	**សមាជិក**
១៥-លោកសាស្ត្រាចារ្យបណ្ឌិត **សោម សុម្មនី**	អនុប្រធានវិទ្យាស្ថាន មនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម	**សមាជិក**

១៦-ឯកឧត្តមបណ្ឌិត ឆយ អូន	សមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌	សមាជិក
១៧-ឯកឧត្តម ឈន អៀម	រដ្ឋលេខាធិការនៃក្រសួងធម្មការ និងកិច្ចការសាសនា	សមាជិក
១៨-ឯកឧត្តម ជា ហឿន	អនុរដ្ឋលេខាធិការនៃក្រសួងធម្មការ និងកិច្ចការសាសនា	សមាជិក
១៩-ឯកឧត្តម ជា គាន	អគ្គលេខាធិការរងទី១ ក្រុមប្រឹក្សាជាតិ រណសិរ្សសាមគ្គី អភិវឌ្ឍន៍មាតុភូមិកម្ពុជា អគ្គលេខាធិការរង គណៈកម្មាធិការជាតិ រៀបចំបុណ្យជាតិ-អន្តរជាតិ	សមាជិក
២០-ឯកឧត្តម សូ មុយឃឿង	សមាជិកគណៈកម្មការបណ្ណិតសភាទទួលបន្ទុក អនុម័តពាក្យច្បាប់	សមាជិក
២១-លោកសាស្ត្រាចារ្យបណ្ឌិត ស៊ីខ ផុស	សមាជិកគណៈកម្មការបណ្ណិតសភាទទួលបន្ទុក អនុម័តពាក្យច្បាប់	សមាជិក
២២-លោកសាស្ត្រាចារ្យបណ្ឌិត ច័ន្ទ សំណព្វ	ប្រធានដេប៉ាតឺម៉ង់ភាសាវិទ្យា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ	សមាជិក
២៣-លោកសាស្ត្រាចារ្យ មៀច ប៉ុណ្ណ	ទីប្រឹក្សាអមក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ	សមាជិក
២៤-លោកសាស្ត្រាចារ្យ ត្រាត់ ត្រាំ		សមាជិក
២៥-លោក មាស គាំ		សមាជិក
២៦-លោក ពៅ ពិសិដ្ឋ	អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការ និងព័ត៌មាន នៃគ.ទ.ក	សមាជិក
២៧-តំណាងក្រសួងអប់រំ យុវជន និងកីឡា		សមាជិក
២៨-តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ		សមាជិក
២៩-តំណាងក្រសួងព័ត៌មាន		សមាជិក

៣០-តំណាងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ **សមាជិក**

៣១-តំណាងក្រសួង និងស្ថាប័ននានា **សមាជិក**

៣២-តំណាងសមាគមអ្នកនិពន្ធខ្មែរ **សមាជិក**

៣៣-តំណាងពុទ្ធសាសនបណ្ឌិត្យ **សមាជិក**

៣៤-លោកសាស្ត្រាចារ្យ **សន ពៅ** លេខាអចិន្ត្រៃយ៍នៃវិទ្យាស្ថានភាសាជាតិ **លេខាធិការ**

៣៥-លោកសាស្ត្រាចារ្យ **ជួរ គារី** ប្រធានផ្នែកខេមរនីយកម្ម វចនានុក្រម និងបកប្រែ នៃវិទ្យាស្ថានភាសាជាតិ **លេខាធិការ**

៣៦-លោកសាស្ត្រាចារ្យ **ស៊ុំ ឈុំប៊ុនរុង** លេខាអចិន្ត្រៃយ៍នៃវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម **លេខាធិការ**

មាត្រា ២.-

គណៈកម្មាធិការជាតិភាសាខ្មែរ មានភារកិច្ចកំណត់ឯកភាពនៃភាសាខ្មែរក្នុងការសរសេរ ការអាន និយមន័យ និងការបង្កើតពាក្យ ជាពិសេសកំណត់គោលនយោបាយជាតិនៃភាសា ដើម្បីអភិវឌ្ឍភាសាខ្មែរ ឱ្យចម្រើនឡើងប្រកបដោយ និរន្តរភាព និងរក្សានូវអត្តសញ្ញាណដ៏ថ្លៃថ្នូរនៃជាតិខ្មែរ ។

នីតិវិធី និងដំណើរការអនុវត្តភារកិច្ចរបស់គណៈកម្មាធិការជាតិភាសាខ្មែរ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង ។

មាត្រា ៣.-

សមាជិក និងទីប្រឹក្សានៃគណៈកម្មាធិការជាតិភាសាខ្មែរ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

តំណាងក្រសួង ស្ថាប័ននានា ដែលទទួលការចាត់តាំងពីសាមីក្រសួង ស្ថាប័ន នឹងត្រូវអញ្ជើញឱ្យចូលរួមប្រជុំតាម ការអញ្ជើញរបស់ប្រធាន ក្នុងករណីចាំបាច់ ។

គណៈកម្មាធិការនេះ ធ្វើការប្រជុំក្រុមការងារបច្ចេកទេសមួយសប្តាហ៍ម្តង និងប្រជុំរួមប្រចាំខែ ។ ប្រធាន គណៈកម្មាធិការជាតិភាសាខ្មែរ មានភារកិច្ចកោះប្រជុំដោយកំណត់ប្រធានបទ ទីកន្លែង និងកាលបរិច្ឆេទនៃការប្រជុំ តាមការចាំបាច់ ។ អនុសាសន៍ ឬគោលនយោបាយភាសាខ្មែរ ដែលស្នើឡើងក្នុងអង្គប្រជុំរួមនីមួយៗ នឹងត្រូវដាក់ជូន ប្រមុខរាជរដ្ឋាភិបាលសម្រាប់ពិចារណា និងចាត់វិធានការអនុវត្តនៅទូទាំងប្រទេស តាមលទ្ធភាពជាក់ស្តែង ។

មាត្រា ៤.-

គណៈកម្មាធិការនេះ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅវិទ្យាស្ថានភាសាជាតិ នៃ រាជបណ្ឌិតសភាកម្ពុជា ជាជំនួយការ ។

លេខាធិការដ្ឋាន ជាអង្គភាពបច្ចេកទេសដែលជួយគណៈកម្មាធិការជាតិភាសាខ្មែរ ក្នុងការងារភាសាខ្មែរ ការងាររដ្ឋបាល និងហិរញ្ញកិច្ច ហើយនិងការងារផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងគណៈកម្មាធិការនេះ ។

សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាននេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការជាតិភាសាខ្មែរ ។

មាត្រា ៥.-

ថវិកាសម្រាប់ធានាដំណើរការក្នុងលេខាធិការដ្ឋាន និងការប្រជុំនានា ជាថវិកាជាតិតាមគម្រោង ដែលស្នើឡើងដោយគណៈកម្មាធិការជាតិភាសាខ្មែរ តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ។

គណៈកម្មាធិការនេះ អាចទទួលជំនួយឧបត្ថម្ភពីសប្បុរសជន ពីអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ហើយនិងពីប្រភពផ្សេងៗទៀត ។

មាត្រា ៦.-

គណៈកម្មាធិការនេះ អាចបង្កើតក្រុមការងារបច្ចេកសព្ទភាសាខ្មែរ និងអនុគណៈកម្មការឯកទេសភាសាខ្មែរផ្សេងៗទៀត តាមសេចក្តីត្រូវការចាំបាច់ ។

មាត្រា ៧.-

គណៈកម្មាធិការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់រាជបណ្ឌិតសភាកម្ពុជា ។

មាត្រា ៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសមាសភាពគណៈកម្មាធិការ ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ១៦៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាឱ្យដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ .ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាសលេខ ១៤០១ សហវ.ប្រក.ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៣៨.៦២២.៥០០.០០០ រៀល (សាមសិបប្រាំបីពាន់ប្រាំមួយរយម្ភៃពីរលានប្រាំរយពាន់រៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦០ (ការទិញ) ចំនួន ១២.២៧៨.១០០.០០០ រៀល ជំពូក ៦១ (សេវាខាងក្រៅ) ចំនួន ១.៥១៦.៧០០.០០០ រៀល ជំពូក ៦២ (សេវាខាងក្រៅផ្សេងៗ) ចំនួន ២៤.២៤២.២០០.០០០ រៀល និង មកជំពូក ៦៤ (បន្ទុកបុគ្គលិក) ចំនួន ៥៨៥.៥០០.០០០ រៀល ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ ២០០៧ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីគោរពជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

អ៊ុក រ៉ាប៊ុន
រដ្ឋមន្ត្រីស្តីទី
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួង សម្រាប់អនុវត្តកាតព្វកិច្ច និងការសន្យារបស់កម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ១១៩៨ / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញសេចក្តីសម្រេចលេខ ៣០ សសរ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការតែងតាំង និងដំណើរប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលការងារជាមួយអង្គការពាណិជ្ជកម្មពិភពលោក
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សម្រេច

មាត្រា ១ : ត្រូវបានបង្កើតគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងមួយ សម្រាប់អនុវត្តកាតព្វកិច្ច និងការសន្យារបស់កម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តមបណ្ឌិត **ចម ប្រសិទ្ធ**	ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម	ប្រធាន
២- ឯកឧត្តម **ប៉ាន សូរស័ក្តិ**	រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	អនុប្រធាន

៣-ឯកឧត្តម	អ៊ុច បូររិទ្ធ	រដ្ឋលេខាធិការក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ	អនុប្រធាន

ទីស្តីការគណៈរដ្ឋមន្ត្រី

៤-ឯកឧត្តម	សេង លឹមនៅ	រដ្ឋលេខាធិការ	សមាជិក
៥-ឯកឧត្តមបណ្ឌិត	ជា វ៉ាន់ដេត	នាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី	សមាជិក
៦-ឯកឧត្តមបណ្ឌិត	ចាប សុធារិទ្ធិ	ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី	សមាជិក
៧-លោក	តឹករ៉េត សំរេច	ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី	សមាជិក

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

៨- ឯកឧត្តម	ហែម សាឯម	ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី	សមាជិក
៩- លោក	អេង ហ៊ុន	ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ	សមាជិក
១០-លោក	ស៊ុន សួន	ប្រធាននាយកដ្ឋានអង្គការអន្តរជាតិ	សមាជិក

ក្រសួងពាណិជ្ជកម្ម

១១- ឯកឧត្តម	ម៉ៅ ថូរ៉ា	អនុរដ្ឋលេខាធិការ	សមាជិក
១២- ឯកឧត្តម	ឈូន ដារ៉ា	អគ្គនាយកបច្ចេកទេស	សមាជិក
១៣- លោក	សុខ សុតំគ្រ	អគ្គនាយករងបច្ចេកទេស	សមាជិក
១៤- លោក	ពេជ ឫទ្ធី	អគ្គនាយករងបច្ចេកទេស	សមាជិក
១៥- លោក	ម៉ក់ ពេជ្ររិទ្ធ	ប្រធាននាយកដ្ឋានកាំកុងត្រូល	សមាជិក
១៦- លោក	ស៊ាង ថៃ	ប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ	សមាជិក
១៧- លោក	មាន សុភា	ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម	សមាជិក
១៨- លោក	ទ៊ា រុតសាន	ប្រធានប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា	សមាជិក
១៩- លោក	ហូ សារ៉ាន់	ប្រធាននាយកដ្ឋាននីតិកម្ម	សមាជិក
២០- លោក	ជូន ថន	ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស	សមាជិក
២១- លោក	អ៊ុន មុនថា	អនុប្រធាននាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស	សមាជិក
២២- លោក	ប៉ែន សុវិជាតិ	អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា	សមាជិក
២៣- លោក	ឈុប សោភ័ណតារា	អនុប្រធាននាយកដ្ឋានអាស៊ាន និងអង្គការអន្តរជាតិ	សមាជិក
២៤- លោក	និត រិទ្ធិពល	ប្រធានការិយាល័យអង្គការពាណិជ្ជកម្មពិភពលោក	សមាជិក

ក្រសួងមហាផ្ទៃ

២៥- ឯកឧត្តម	ទី ចំនួនផល	អនុរដ្ឋលេខាធិការ	សមាជិក
២៦- ឯកឧត្តម	សក់ សេដ្ឋា	អគ្គនាយករដ្ឋបាល	សមាជិក
២៧- ឧត្តមសេនីយ៍ត្រី	កែវ ចណ្ណថន	អនុប្រធានទី ១ ការិយាល័យកណ្តាលនគរបាលអន្តរជាតិ	សមាជិក

ក្រសួងការពារជាតិ

២៨- ឯកឧត្តម	ជុំ សម្បូន	អនុរដ្ឋលេខាធិការ	សមាជិក
២៩- ឯកឧត្តមឧត្តមសេនីយ៍ឯក	ទេព ម៉ិនឡាយ	អគ្គនាយករង អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ	សមាជិក
៣០- ឯកឧត្តមឧត្តមសេនីយ៍ទោ	ម៉ម សុផាត	នាយក នាយកដ្ឋាននីតិកម្ម	សមាជិក
៣១- ឯកឧត្តមឧត្តមសេនីយ៍ត្រី	រស់ ផន	នាយករង នាយកដ្ឋាននយោបាយ និងផែនការ	សមាជិក

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៣២- ឯកឧត្តម	គង់ ទ័ណ្ឌល	រដ្ឋលេខាធិការទី ១	សមាជិក
៣៣- ឯកឧត្តម	ស្រ៊ុន ដារា	អនុរដ្ឋលេខាធិការ	សមាជិក
៣៤- លោក	អ៊ុយ សម្បត្តិ	ប្រធាននាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន	សមាជិក
៣៥- លោក	គុណ ញឹម	នាយករងទីចាត់ការគយ និងរដ្ឋាករ	សមាជិក
៣៦- លោក	អ៊ុំ ស៊ីហា	អនុប្រធានទី ១ នាយកដ្ឋានពន្ធដារ	សមាជិក
៣៧- លោក	គឹម សុគៈ	អនុប្រធាននាយកដ្ឋានពន្ធដារ	សមាជិក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៣៨- ឯកឧត្តម	ចំរួន តុងអ៊ីវ	រដ្ឋលេខាធិការ	សមាជិក
៣៩- ឯកឧត្តម	គុំ សារ៉ុន	អគ្គនាយក	សមាជិក
៤០- លោក	ម៉ែន ខុង	ប្រធាននាយកដ្ឋានក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម	សមាជិក
៤១- លោក	ឱ្មត សារ៉ាឌុង	ប្រធាននាយកដ្ឋានផែនការស្ថិតិ និងសហប្រតិបត្តិការ អន្តរជាតិ	សមាជិក

ក្រសួងអភិវឌ្ឍន៍ជនបទ

៤២- ឯកឧត្តម	សួស គង់	រដ្ឋលេខាធិការ	សមាជិក
៤៣- ឯកឧត្តម	សៅ ជីវ័ន្ត	អនុរដ្ឋលេខាធិការ	សមាជិក

៤៤- លោក	ផាន់ សារឿន	ប្រធាននាយកដ្ឋានសេដ្ឋកិច្ចជនបទ	សមាជិក
៤៥- លោក	ឡុច រៀមដែត	ប្រធានការិយាល័យទំនាក់ទំនងទីផ្សារ	សមាជិក

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

៤៦- ឯកឧត្តម	អ៊ិត ប្រាំង	រដ្ឋលេខាធិការ	សមាជិក
៤៧- លោក	សាត សមុទ្រ	អគ្គនាយករង	សមាជិក
៤៨- លោក	ពឹង ស៊ីវឡាយ	ប្រធាននាយកដ្ឋានស្តង់ដារឧស្សាហកម្មកម្ពុជា	សមាជិក
៤៩- លោក	ខែត ទិមុល	ប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម	សមាជិក

ក្រសួងផែនការ

៥០- ឯកឧត្តម	ឆឹង ចំរើន	រដ្ឋលេខាធិការ	សមាជិក
៥១- ឯកឧត្តម	ខួន ថាវរៈ	អគ្គនាយក	សមាជិក
៥២- លោក	សួន សុខឃីម	ប្រធាននាយកដ្ឋាន	សមាជិក
៥៣- លោក	ហួយ សិទ្ធិគុណ	អនុប្រធាននាយកដ្ឋាន	សមាជិក

ក្រសួងអប់រំ យុវជន និងកីឡា

៥៤- ឯកឧត្តម	ឌៀ ថេន	រដ្ឋលេខាធិការ	សមាជិក
៥៥- ឯកឧត្តម	តើ ណៃលាង	អគ្គនាយកអប់រំ	សមាជិក
៥៦- លោក	សំ សើរតន៍	ប្រធាននាយកដ្ឋានផែនការ	សមាជិក
៥៧- លោក	លី សិទ្ធិ	ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ	សមាជិក
៥៨- លោក	ថោង បូរ៉ាន់	ប្រធាននាយកដ្ឋានបុគ្គលិក	សមាជិក
៥៩- លោក	វត្ថី សុខា	ប្រធាននាយកដ្ឋានឧត្តមសិក្សា	សមាជិក

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

៦០- ឯកឧត្តម	សយ ស៊ីផុន	រដ្ឋលេខាធិការ	សមាជិក
៦១- ឯកឧត្តម	កែម បុររត្ន	អគ្គនាយកបច្ចេកទេស	សមាជិក
៦២- លោក	លឹម អែលឡូរ៉ង់	ប្រធាននាយកដ្ឋានផែនការ សរុប និងស្ថិតិ	សមាជិក
៦៣- លោក	ញៀម ចាន់ណេ	ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ	សមាជិក

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

៦៤-	ឯកឧត្តម	ម៉ម សុផាណា	អនុរដ្ឋលេខាធិការ	សមាជិក
៦៥-	លោក	ហ៊ុយ ណារ៉ា	អគ្គនាយករង	សមាជិក
៦៦-	លោក	ហ៊ុយ ផាប់	អនុប្រធាននាយកដ្ឋានអភិរក្សសុរិយោដី	សមាជិក

ក្រសួងបរិស្ថាន

៦៧-	ឯកឧត្តម	ខុន សំនួន	រដ្ឋលេខាធិការ	សមាជិក
៦៨-	ឯកឧត្តម	ឡុញ ឃីរ៉ាល	អគ្គនាយកបច្ចេកទេស	សមាជិក
៦៩-	លោក	ហេង ណារ៉េត	ប្រធាននាយកដ្ឋានត្រួតពិនិត្យការបំពុលបរិស្ថាន	សមាជិក

ក្រសួងធនធានទឹក និងឧតុនិយម

៧០-	ឯកឧត្តម	ទេង សាខុន	រដ្ឋលេខាធិការ	សមាជិក
៧១-	លោក	ថេង តារា	ប្រធានគ្រប់គ្រង និងអភិរក្សធនធានទឹក	សមាជិក
៧២-	លោក	ឈា ប៊ុនរិទ្ធ	អនុប្រធាននាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក

ក្រសួងព័ត៌មាន

៧៣-	ឯកឧត្តម	អ៊ុំ លន់	អនុរដ្ឋលេខាធិការ	សមាជិក
៧៤-	លោក	រស់ រតនា	អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ	សមាជិក

ក្រសួងយុត្តិធម៌

៧៥-	ឯកឧត្តម	ចាន់ ហួន	រដ្ឋលេខាធិការ	សមាជិក
៧៦-	លោក	ម៉ែន ពេជ្រសាលី	ប្រធាននាយកដ្ឋានកិច្ចការអន្តរជាតិ	សមាជិក
៧៧-	លោក	ញៀម ចន្ទរ៉េត	អនុប្រធាននាយកដ្ឋានកិច្ចការអន្តរជាតិ	សមាជិក
៧៨-	លោក	ស៊ឹង សារ៉ាត់	ប្រធានការិយាល័យ	សមាជិក

ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

៧៩-	ឯកឧត្តម	ឆេង សារឿន	រដ្ឋលេខាធិការ	សមាជិក
៨០-	ឯកឧត្តម	ពូ ដារ៉ានី	អនុរដ្ឋលេខាធិការ	សមាជិក
៨១-	លោក	តៅ សាន់ឌី	មន្ត្រី	សមាជិក

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

៨២-ឯកឧត្តម	ជិន ប៊ុនសៀន	រដ្ឋលេខាធិការ	សមាជិក
៨៣- ឯកឧត្តម	មាស ប៉ូ	អគ្គនាយក	សមាជិក
៨៤- លោកស្រី	ឡេ ម៉ាយគៀង	អគ្គនាយករងប្រៃសណីយ៍ និងទូរគមនាគមន៍	សមាជិក
៨៥- លោក	គ្រីង ឌូម៉ា	អនុប្រធាននាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត និងទំនាក់ទំនងអន្តរជាតិ	សមាជិក

ក្រសួងសុខាភិបាល

៨៦- ឯកឧត្តម	អ៊ឹង គីរុន	រដ្ឋលេខាធិការ	សមាជិក
៨៧- ឯកឧត្តម	សុខ ផេង	អនុរដ្ឋលេខាធិការ	សមាជិក
៨៨- លោក	ជូ យិនស៊ឹម	អនុរដ្ឋលេខាធិការ	សមាជិក
៨៩- លោក	ជី មានហៀ	អគ្គនាយករងបច្ចេកទេស	សមាជិក
៩០- លោក	ច្រឹង សុខន	អនុប្រធាននាយកដ្ឋាន	សមាជិក
៩១- លោក	ឈៀង ដារណា	អនុប្រធាននាយកដ្ឋានឱសថ-ជំណីអាហារ	សមាជិក
៩២- លោក	ហេង ហួត	ប្រធានការិយាល័យនិយ័តកម្មឱសថ	សមាជិក

ក្រសួងសាធារណការ និងដឹកជញ្ជូន

៩៣- ឯកឧត្តម	កែប ថន	អនុរដ្ឋលេខាធិការ	សមាជិក
៩៤- លោក	ចាន់ តារា	អគ្គនាយករង នៃអគ្គនាយកដ្ឋានដឹកជញ្ជូន	សមាជិក
៩៥- លោក	ម៉ក់ ស៊ីដេត	ប្រធាននាយកដ្ឋាននាវាសមុទ្រ	សមាជិក
៩៦- លោក	សុខុម ទិរៈផល	ប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវទឹក	សមាជិក
៩៧- លោក	ស្រី សិរីវឌ្ឍន៍	អនុប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោក	សមាជិក
៩៨- លោក	ជាម សុវណ្ណនី	អនុប្រធាននាយកដ្ឋានផែនការ	សមាជិក
៩៩- លោក	អៀង ទេងស៊ុន	នាយកអាជីវកម្មកំពង់ផែភ្នំពេញ	សមាជិក
១០០-លោក	ពៅ ឡាធី	ប្រធានការិយាល័យនីតិកម្ម នៃនាយកដ្ឋានរដ្ឋបាល	សមាជិក

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

១០១-ឯកឧត្តម	សំរ៉ាំង កំសាន្ត	អនុរដ្ឋលេខាធិការ	សមាជិក
១០២-ឯកឧត្តម	ស៊ឹម សារ៉ាក់	អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ	សមាជិក
១០៣-លោក	អ៊ុន ឆឹម	អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ	សមាជិក

១០៤-លោក	លឹម យូសួ	អនុប្រធាននាយកដ្ឋាន	សមាជិក

ក្រសួងទេសចរណ៍

១០៥-ឯកឧត្តម	ថោង ខុន	រដ្ឋលេខាធិការ	សមាជិក
១០៦-លោក	ហោ សារុន	អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ	សមាជិក
១០៧-លោក	ឈុន ណាក់	អនុប្រធាននាយកដ្ឋានអាស៊ាន និងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
១០៨-លោក	សោម ម៉ិនណាត	ប្រធានការិយាល័យអង្គការអន្តរជាតិ	សមាជិក

ក្រសួងធម្មការ និងសាសនា

១០៩-ឯកឧត្តម	ឈឹម អៀម	រដ្ឋលេខាធិការ	សមាជិក
១១០-ឯកឧត្តម	ហ៊ីង គឹមថន	អនុរដ្ឋលេខាធិការ	សមាជិក
១១១-លោក	ខួន ច័ន្ទធន្នី	នាយកពុទ្ធសាសនបណ្ឌិត្យ	សមាជិក
១១២-លោក	អ៊ឹង សុភារិទ្ធ	អនុប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ	សមាជិក

ក្រសួងកិច្ចការនារី

១១៣-លោកជំទាវ	អ៊ឹង កន្ថាផាវី	រដ្ឋមន្ត្រី	សមាជិក
១១៤-លោកជំទាវ	កេត សំអាត	អនុរដ្ឋលេខាធិការ	សមាជិក
១១៥-លោកស្រី	ម៉ិនឈិត ខាសនា	ប្រធានការិយាល័យ	សមាជិក

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១១៦-ឯកឧត្តម	អ៊ុំ មាន	អនុរដ្ឋលេខាធិការ	សមាជិក
១១៧-លោក	ហ៊ូ ឋុន្នី	អគ្គនាយករង	សមាជិក
១១៨-លោក	ឃួត ចាន់ធី	ប្រធាននាយកដ្ឋានអធិការកិច្ចការងារ	សមាជិក
១១៩-លោក	ឌី សេរីវុទ្ធ	នាយកខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី	សមាជិក

រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

១២០-លោក	នូ សុខណ្ណា	អគ្គនាយករងរដ្ឋបាល	សមាជិក
១២១-លោក	ខៀវ ច័ន្ទម៉ិនធឿន	ប្រធាននាយកដ្ឋានក្របខ័ណ្ឌ	សមាជិក

១២២-ឯកឧត្តម	កែវ សាផល	អនុរដ្ឋលេខាធិការ	សមាជិក
១២៣-លោក	ស៊ិន ចាន់សេរីវុត្ថា	ប្រធាននាយកដ្ឋានផែនការនីតិកម្ម	សមាជិក
១២៤-លោក	អ៊ិន ចិសាលភាព	អនុប្រធានាយកដ្ឋានដឹកជញ្ជូន	សមាជិក

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

១២៥-ឯកឧត្តម	សុខ ចិន្តា	អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
១២៦-ឯកឧត្តម	សួន សិទ្ធី	អគ្គលេខាធិការរង ក.អ.ក និង គ.វ.ក	សមាជិក
១២៧-ឯកឧត្តម	ជា វុទ្ធី	អគ្គលេខាធិការរងតំបន់សេដ្ឋកិច្ចពិសេស	សមាជិក
១២៨-លោក	អន សុផាណារ៉ា	ប្រធាននាយកដ្ឋាននីតិកម្ម និងច្បាប់វិនិយោគ	សមាជិក
១២៩-លោកស្រី	ដេង សុភាព	អនុប្រធាននាយកដ្ឋានសម្របសម្រួលកិច្ចការអន្តរក្រសួង	សមាជិក

ធនាគារជាតិនៃកម្ពុជា

១៣០-លោកជំទាវ	គាល់ ណែរអ៊ីម	អគ្គនាយក	សមាជិក
១៣១-លោកស្រី	ខួន សុខា	ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងស្ថិតិ	សមាជិក

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

១៣២-មេធាវី	នូ ធេតិរិទ្ធ	សមាជិកក្រុមប្រឹក្សាគណៈមេធាវី	សមាជិក
១៣៣-មេធាវី	ហែម ហួណារិទ្ធ	សមាជិកគណៈមេធាវី	សមាជិក

ក្នុងករណីមន្ត្រី ដែលជាសមាជិកគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួង មិនអាចបំពេញការងាររបស់ខ្លួនបាន ដោយសារមូលហេតុផ្សេងៗ សាមីក្រសួងត្រូវជ្រើសរើសមន្ត្រី ដែលមានឋានៈ និងបទពិសោធន៍ប្រហាក់ប្រហែលមកជំនួសវិញ ដោយគ្រាន់តែធ្វើលិខិតបញ្ជូនមកប្រធានគណៈកម្មាធិការ ដើម្បីសុំប្តូរ និងចម្លងជូនដំណឹងទៅទីស្តីការគណៈរដ្ឋមន្ត្រី។

មាត្រា ២ : គណៈកម្មាធិការសម្របសម្រួលអន្តរក្រសួង មានភារកិច្ចដូចតទៅ :

- ធានាអនុវត្តឱ្យបានសម្រេចនូវកម្មវិធីការងាររបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធទៅនឹងអង្គការពាណិជ្ជកម្មពិភពលោក ដោយធ្វើការណែនាំ និងត្រួតពិនិត្យដំណើរការរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ក្នុងការបំពេញភារកិច្ចតាមកម្មវិធីការងាររបស់ខ្លួន និងរាយការណ៍ជូនគណៈរដ្ឋមន្ត្រីជាប្រចាំ យ៉ាងហោចណាស់រៀងរាល់ ៦ ខែ ម្តង។
- ណែនាំឱ្យមានការរៀបចំផែនការសកម្មភាពសម្រាប់តាមក្រសួង-ស្ថាប័នពាក់ព័ន្ធ អនុវត្តកាតព្វកិច្ចឱ្យស្របតាមការសន្យារបស់កម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក។

